**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១២៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការដំឡើងសាខាគយនិងរដ្ឋាករចំនួន ២ ទៅជានាយកដ្ឋានស្ថិតក្រោមឱវាទ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានដំឡើងសាខាគយនិងរដ្ឋាករចំនួន ២ ឱ្យទៅជានាយកដ្ឋាន ស្ថិតក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

- សាខាគយនិងរដ្ឋាករផែស្ងួត ត្រូវបានដំឡើងទៅជានាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត
- សាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ ត្រូវបានដំឡើងទៅជានាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ។

អង្គការលេខរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២.-**

នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាលើការងារសម្រួលពាណិជ្ជកម្ម និងអនុលោមភាពតាមបណ្តាផែស្ងួតនានា ដោយមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងតាមឋានានុក្រមលើបណ្តាការិយាល័យគយនិងរដ្ឋាករប្រចាំសន្និធិគយបណ្តោះអាសន្ន និងភណ្ឌាគារគយមានដែនកំណត់នានា តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធអាករលើទំនិញនាំចេញ-នាំចូល សន្និធិ និងឆ្លងកាត់គ្រប់ប្រភេទ រួមទាំងអីវ៉ាន់អ្នកដំណើរ រូបិយប័ណ្ណ លោហជាតុ ត្បូងថ្មមានតម្លៃ
- ចាត់វិធានការ សហការស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើស ជាពិសេសបទល្មើសគយនានា ក្នុងដែនសមត្ថកិច្ចរបស់សាមីអង្គភាព
- ចូលរួមកសាង និងរៀបចំនូវគោលនយោបាយ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការនាំចេញ-នាំចូល និងឆ្លងកាត់តាមផែស្ងួតនានា ដើម្បីជំរុញប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមការអនុវត្តល្អជាអន្តរជាតិ
- រៀបចំ កត់ត្រា ចងក្រង និងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់នាយកដ្ឋាន
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាល លិខិតចេញ-ចូលផ្សេងៗ បូកសរុប និងធ្វើរបាយការណ៍លទ្ធផលការងាររបស់នាយកដ្ឋាន
- រៀបចំផែនការសកម្មភាព និងផែនការចំណាយថវិការបស់នាយកដ្ឋាន
- គ្រប់គ្រងធនធានមនុស្ស ស្ថិតិទិន្នន័យ តារាងព័ត៌មាន និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្នុងនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**មាត្រា៣.-**

នាយកដ្ឋានគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាលើការងារសម្រួលពាណិជ្ជកម្ម និងអនុលោមភាពនៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិនានា ដោយមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងតាមឋានានុក្រមលើបណ្តាការិយាល័យគយនិងរដ្ឋាករនានានៅតាមបណ្តាអាកាសយានដ្ឋានអន្តរជាតិនានា
- អនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងគោលនយោបាយនៃការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ ពាក់ព័ន្ធនឹងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធលើទំនិញនាំចេញ-នាំចូល សន្និធិ និងឆ្លងកាត់គ្រប់ប្រភេទតាមផ្លូវអាកាស រួមទាំងអីវ៉ាន់អ្នកដំណើរ រូបិយប័ណ្ណ លោហធាតុ ត្បូងថ្មមានតម្លៃ បេតិកភណ្ឌវប្បធម៌ និងភណ្ឌិកាប្រៃសណីយ៍ ជាដើម
- ចាត់វិធានការស្រាវជ្រាវ និងទប់ស្កាត់ បង្ក្រាបរាល់អំពើរត់ពន្ធគយ រត់ពន្ធគ្រឿងញៀន និងទំនិញហាមឃាត់នានា ក្នុងដែនសមត្ថកិច្ចរបស់សាមីអង្គភាព
- ត្រួតពិនិត្យបែបបទគយលើអាកាសយានចូលក្នុង និងចេញពីដែនគយ តាមការអនុវត្តល្អជាអន្តរជាតិ
- ចូលរួមកសាង និងរៀបចំនូវគោលនយោបាយ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការនាំចេញ-នាំចូលតាមផ្លូវអាកាស ដើម្បីជំរុញប្រសិទ្ធភាពនៃកិច្ចសម្រួលពាណិជ្ជកម្មតាមការអនុវត្តល្អជាអន្តរជាតិ
- រៀបចំ កត់ត្រា ចងក្រង និងគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់នាយកដ្ឋាន
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាល លិខិតចេញ-ចូលផ្សេងៗ បូកសរុប និងធ្វើរបាយការណ៍លទ្ធផលការងាររបស់នាយកដ្ឋាន
- រៀបចំផែនការសកម្មភាព និងផែនការចំណាយថវិការបស់នាយកដ្ឋាន
- គ្រប់គ្រងធនធានមនុស្ស ស្ថិតិទិន្នន័យតារាងព័ត៌មាន និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្នុងនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**មាត្រា៤**.-

នាយកដ្ឋាននីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥**.-

ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពថ្នាក់ក្រោមនាយកដ្ឋានក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា៦**.-

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលកំពុងអនុវត្តត្រូវបន្តអានុភាពអនុវត្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៧.-**

អនុក្រឹត្យនេះត្រូវបំពេញបន្ថែមអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៤ រោច ខែ ជេស្ឋ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ

### នៃអនុក្រឹត្យលេខ...១១៦... អនក្រ.បក ចុះថ្ងៃទី...៥...ខែធ្នូ... ឆ្នាំ២០២៣
### ស្តីពីការដំឡើងសាខាគយនិងរដ្ឋាករចំនួន ២ ទៅជានាយកដ្ឋានស្ថិតក្រោមឱវាទ
### អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## អង្គការលេខរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

